គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីវេទិកាជាតិអន្តរសាសនាលើកទី៦
# ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# ក្រោមប្រធានបទ៖ « សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស! »

## របាយការណ៍សង្ខេប
## ស្តីពី ស្ថានភាពអំពើជួញដូរមនុស្ស និងការចូលរួមរបស់សាសនា ក្នុងការប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា

ថ្លែងដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ក្នុងពិធីវេទិកាជាតិអន្តរសាសនា ប្រឆាំងការជួញដូរមនុស្ស

ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹងថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ

- សូមថ្វាយបង្គំ សម្តេចព្រះមហាសង្ឃរាជាទាំងពីរគណៈ សម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃនាយក ព្រះសង្ឃនាយករង ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សម្តេច ឯកឧត្តម លោកជំទាវ សមាជិកដ៏ឧត្តុង្គឧត្តមនៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃបណ្តាក្រសួងស្ថាប័ន
- ឯកឧត្តម លោកជំទាវ ជាតំណាងអង្គទូត និងស្ថានតំណាងនៃបណ្តាប្រទេសជាមិត្តប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- តំណាងនិកាយសាសនា យាយជី តាជី លោកគ្រូ អ្នកគ្រូ សិស្សនិស្សិត និងបងប្អូនជនរួមជាតិជាទីស្រឡាញ់រាប់អាន

ថ្ងៃនេះ គឺជាការប្រារព្ធពិធីវេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្សលើកទី៦ ដោយគិតចាប់ពីឆ្នាំ២០១៧មក ដែលកម្មវិធីនេះ ត្រូវបានប្រព្រឹត្តទៅយ៉ាងអធឹកអធម និងបានបញ្ជាក់អំពីភាពសុខដុមរមនានៃ

សាសនាទាំងឡាយនៅកម្ពុជា ។ កម្មវិធីនេះ មានការចូលរួមប្រកបដោយឆន្ទៈមុះមុត ពីថ្នាក់ដឹកនាំ និងបព្វជិតនៃនិកាយសាសនាទាំងឡាយ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាទម្រង់អមនុស្សធម៌មួយនៃការរំលោភបំពានលើសិទ្ធិ សេរីភាព និងកេងប្រវ័ញ្ចលើរាងកាយ សតិបញ្ញា កម្លាំងពលំ របស់មនុស្សយ៉ាងធ្ងន់ធ្ងរដើម្បីតែផលប្រយោជន៍របស់ឧក្រិដ្ឋជន និងមិនខ្វាយខ្វល់ពីការវិនាសអន្តរាយរបស់អ្នកណាទាំងអស់ ។ ឆ្លៀតក្នុងឱកាសដ៏នក្ខត្តឫក្សនេះ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគោលនយោបាយប្រកបដោយទស្សនវិស័យដ៏ទូលំទូលាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា និងថ្នាក់ដឹកនាំក្នុងស្ថាប័នកំពូលនៃរាជរដ្ឋាភិបាល ដោយបានតម្កល់ខ្ពស់នូវជំនឿសាសនា ដែលមានការអប់រំខ្ពស់ផ្នែកស្មារតី និងឥរិយាបទក្នុងការរស់នៅ ឲ្យប្រកបដោយគុណធម៌ និងអាចបញ្ចៀសបានពីអំពើឧក្រិដ្ឋបំផ្លាញសង្គមប្រកបដោយប្រសិទ្ធភាព។ ច្បាប់តែម្យ៉ាងមិនគ្រប់គ្រាន់នឹងធ្វើឲ្យមនុស្សមានការកែប្រែឥរិយាបទ និងផ្នត់គំនិតទេ តែការអប់រំមនុស្សដោយទន់ភ្លន់តាមបែបសាសនា ធ្វើឲ្យមនុស្សមានស្មារតីភ្ញាក់រលឹក ស្គាល់ខុស ស្គាល់ត្រូវ និងខិតខំកសាងខ្លួនឲ្យក្លាយជាមនុស្សល្អក្នុងសង្គមបាន ។ ក្នុងកម្មវិធីអន្តរសាសនាប្រឆាំងការជួញដូរមនុស្សប្រាំមួយលើកកន្លងមកនេះ មានការចូលរួមពីនិកាយនៃសាសនាធំៗ បី គឺ ព្រះពុទ្ធសាសនា ឥស្លាមសាសនាកម្ពុជា និងគ្រិស្តសាសនា ប្រកបដោយឆន្ទៈ និងបានព្រមព្រៀងគ្នាស្វែងរកវិធីសាស្ត្រ ដើម្បីអប់រំ ទូន្មាន ប្រៀនប្រដៅមនុស្សទាំងឡាយ ឲ្យប្រព្រឹត្តនូវអំពើល្អ ចេះស្រឡាញ់ខ្លួនឯង ស្រឡាញ់គ្រួសារ ស្រឡាញ់មនុស្សជាតិ និងចេះជួយការពារគ្នាទៅវិញទៅមក មិនសាងបាបគ្រោះលើអ្នកដទៃឲ្យរងទុក្ខដោយសារខ្លួន ។

ឆ្នាំនេះ វេទិកាអន្តរសាសនាកម្ពុជាបានលើកយកប្រធានបទរួមមួយគឺ «**សូមកុំយកកម្ពុជា ជាគោលដៅប្រព្រឹត្តអំពើជួញដូរមនុស្ស!**» ដែលជាការអំពាវនាវផង និងប្រឆាំងផង ចំពោះរាល់សកម្មភាពទុច្ចរិតដែលប្រព្រឹត្តក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទៅលើប្រជាជនកម្ពុជា ក៏ដូចជាជនបរទេស ដែលអំពើដ៏ឃោរឃៅនេះ បានបំផ្លាញទាំងធនធានមនុស្ស ទាំងកិត្តិយស ទាំងភាពសុខដុមរមនារបស់សង្គមជាតិ ។ កន្លងមក មានប្រជាជនកម្ពុជា ជាច្រើនដែលបានធ្វើទេសន្តប្រវេសន៍ ស្វែងរកការងារនៅក្រៅប្រទេស ដោយប្រថុយប្រថាន ក្នុងនោះមួយចំនួនត្រូវបានរងទុក្ខវេទនាក្នុងទម្រង់ជាការងារបង្ខំ និងលំបាកយ៉ាប់យ៉ឺន មិនបានទទួលកម្រៃប្រាក់ឈ្នួលតាមសន្យា ហើយក៏ត្រូវបានគេជួញដូរ កេងប្រវ័ញ្ច និងប្រើប្រាស់ដោយបង្ខំ ។ ខ្លះ បានបាត់បង់ជីវិត ឬបាត់ដំណឹងមិនបានវិលត្រឡប់មកជួបក្រុមគ្រួសារ ឬធ្លាក់ខ្លួនពិការ បាត់បង់កាយសម្បទា ឬបញ្ញាស្មារតី និងកំពុងស្ថិតនៅក្នុងស្ថានភាពជាជនទេសន្តប្រវេសន៍ដែលគ្មានឯកសារច្បាប់ត្រឹមត្រូវ ធ្វើឲ្យជនល្មើសងាយស្រួលធ្វើសកម្មភាពប្រើប្រាស់ដោយកេងប្រវ័ញ្ច និងរំលោភបំពាន ។ រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងដោះស្រាយករណីជាច្រើន និងនៅតែបន្តដោះស្រាយជាបន្តបន្ទាប់ ហើយក៏បានបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបទល្មើសជាច្រើនដែលនាំដល់ការជួញដូរមនុស្ស រួមទាំងការនាំមនុស្សចេញឆ្លងដែនដោយខុសច្បាប់ ដើម្បីសង្គ្រោះប្រជាពលរដ្ឋពីភាពរងគ្រោះ និងបញ្ជូនជនប្រព្រឹត្តបទល្មើសទៅផ្តន្ទាទោសតាមច្បាប់កំណត់។ សកម្មភាពបង្ក្រាប បានកើនឡើងទ្វេដង ក្នុងឆ្នាំ២០២១ បើប្រៀបធៀបនឹងឆ្នាំ២០២០ បើទោះបីជា

ក្នុងអំឡុងពេលនោះ កម្ពុជាកំពុងស្ថិតក្នុងការញាំញីដោយការរាតត្បាតនៃជំងឺកូវីដ-១៩ក៏ដោយ ។ ក្នុងពេលជាមួយគ្នានេះ ពលករកម្ពុជាដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស ឬវិលត្រឡប់ក្នុងអំឡុងពេលនៃការប្រកាសបិទព្រំដែន ដោយសារគោលការណ៍នៃការទប់ស្កាត់ការឆ្លងរាលដាលនៃកូវីដ-១៩ ក៏ត្រូវបានកើនឡើង ។ មកដល់បច្ចុប្បន្ននេះ មានប្រជាពលរដ្ឋកម្ពុជា ប្រមាណ៣០ម៉ឺននាក់ បានវិលត្រឡប់ ឬត្រូវបានបញ្ជូនត្រឡប់មកកម្ពុជាវិញដោយអាជ្ញាធរបរទេស ហើយត្រូវទទួលបាននូវការគាំពារយ៉ាងយកចិត្តទុកដាក់ពីសមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់។ មកដល់ដើមឆ្នាំ២០២២ សភាពការណ៍កូវីដ-១៩ នៅកម្ពុជាបានធូរស្រាលដែលជាហេតុនាំឲ្យរាជរដ្ឋាភិបាលត្រូវចាប់ផ្ដើមសកម្មភាពសេដ្ឋកិច្ចពាណិជ្ជកម្មឡើងវិញយ៉ាងសកម្ម នៅទូទាំងប្រទេស ក្នុងគន្លងប្រក្រតីភាពថ្មី ។

ទន្ទឹមនឹងស្ថានភាពដ៏ប្រសើរនេះ បែរជាមានរឿងដែលគួរឲ្យសោកស្ដាយ គឺនៅក្នុងពេលថ្មីៗនេះ ក៏មានលេចចេញនូវបទល្មើសថ្មីៗ ដែលកើតឡើងក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា នោះគឺជនល្មើសបានលាក់បំពួនធ្វើសកម្មភាពបទល្មើសឆបោកតាមប្រព័ន្ធទូរគមនាគមន៍យ៉ាងគគ្រឹកគគ្រេង ព្រមជាមួយនឹងការប្រើប្រាស់មនុស្សដោយបង្ខំ កេងប្រវ័ញ្ចប្រាក់ឈ្នួល បិទសិទ្ធិសេរីភាព និងប្រើប្រាស់ជនរងគ្រោះជាឧបករណ៍សម្រាប់បម្រើការបោកប្រាស់អ្នកដទៃទៀត និងធ្វើឲ្យកម្ពុជារងផលប៉ះពាល់ជាអវិជ្ជមាន ដោយទទួលបានការវាយតម្លៃពីសហរដ្ឋអាមេរិក ក្នុងចំណាត់ថ្នាក់លេខ ៣ ដែលមានន័យថាជាប្រទេសដែលមានកិច្ចខិតខំប្រឹងប្រែងតិចតួចក្នុងសកម្មភាពប្រឆាំងការជួញដូរមនុស្ស ។ ជាក់ស្ដែង បទល្មើសនេះ គឺជាទម្រង់ឧក្រិដ្ឋកម្មឆ្លងដែន ដែលមានបណ្ដាញចាត់តាំងនៅរាយប៉ាយតាមបណ្ដោយប្រទេសនានាក្នុងនិងក្រៅតំបន់ និងត្រូវបានក្រុមឧក្រិដ្ឋជនលួចលាក់ធ្វើសកម្មភាពយ៉ាងសម្ងាត់ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងរូបភាពល្បែង និងប្រើឧបាយកលឆបោកវិនិយោគិន ក្នុងគោលដៅអូសទាញអ្នកដែលចាញ់កលល្បិច ដើម្បីកេងប្រវ័ញ្ចប្រមូលធនធានយ៉ាងអាថ៌កំបាំង និងបង្ខំមនុស្សឲ្យធ្វើការលើសម៉ោង ក្នុងកន្លែងបិទជិត មិនឲ្យមានសេរីភាព រហូតដល់មានការធ្វើទារុណកម្ម និងជម្រិតទារប្រាក់ពីគ្រួសារ ជាដើម ។ ជនល្មើសមួយចំនួនបានលួចលាក់ប្រើអាវុធខុសច្បាប់បន្ថែមទៀត ដែលសកម្មភាពនេះ ជាការគម្រាមកំហែងដល់សន្តិសុខជាតិយ៉ាងធ្ងន់ធ្ងរ ។

ក្នុងស្ថានភាពដ៏អាក្រក់នេះ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ មិនបានព្រងើយកន្តើយឡើយ ហើយបានដាក់ចេញផែនការលេខ ១៤៣/២២ ផ.ក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ ជាផែនការប្រតិបត្តិការ បង្កើនការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ការជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ដើម្បីធ្វើឲ្យសម្រេចគោលការណ៍សំខាន់បួនយ៉ាងគឺ **(១)**.សង្គ្រោះជនរងគ្រោះឲ្យបានទាន់ពេលវេលា **(២)**.ស៊ើបអង្កេតរកជនប្រព្រឹត្តបទល្មើស និងបក្សពួក និងស្រាវជ្រាវរកមេខ្លោងដើម្បីផ្ដន្ទាទោសតាមច្បាប់ដោយគ្មានការលើកលែង **(៣)**.ត្រួតពិនិត្យ ប្រមូលភស្តុតាង ដើម្បីបិទអាជីវកម្មខុសច្បាប់ ជាពិសេស ល្បែងស៊ីសង និងល្បែងតាមប្រព័ន្ធអេឡិចត្រូនិកដែលខុសច្បាប់ **(៤)**.បើរកឃើញថាជាករណីជួញដូរមនុស្ស សមត្ថកិច្ចត្រូវពន្លាតការស៊ើបអង្កេតរកសកម្មភាពបទល្មើសសម្អាតប្រាក់ថែមទៀត ដើម្បីបោសសម្អាតបទល្មើសឧក្រិដ្ឋដែលពាក់ព័ន្ធ ។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

បានប្រកាសចេញនូវសេចក្តីអំពាវនាវដល់ស្ថានតំណាងបេសកកម្មការទូតនានា និងសាធារណជន ដែលបានដឹង និងស្គាល់ទីតាំងដែលប្រព្រឹត្តបទល្មើស ឲ្យជួយសហការក្នុងការផ្តល់ព័ត៌មាន មកក្រុមការងារប្រតិបត្តិការ តាមប្រព័ន្ធហ្វេសប៊ុកផ្លូវការរបស់ខ្ញុំ ឬរបស់ក្រសួងមហាផ្ទៃ ឬរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ និងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏ដូចជាតាមប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ផងដែរ ។

ដើម្បីធ្វើឲ្យផែនការប្រតិបត្តិការនេះទទួលបានជោគជ័យ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស បានបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីធ្វើជាយន្តការអនុវត្ត ឲ្យប្រកបដោយប្រសិទ្ធភាព ក្នុងនោះមានជាអាទិ៍ គណៈបញ្ជាការដឹកនាំប្រតិបត្តិការ ដឹកនាំដោយ**ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងក្រុមការងារចំណុះចំនួនប្រាំទៀត ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានចេញលិខិតបង្គាប់ការ បង្កើតក្រុមការងារចំពោះកិច្ច ដឹកនាំដោយឯកឧត្តម កេង សុម៉ារិទ្ធ រដ្ឋលេខាធិការក្រសួងយុត្តិធម៌ ដើម្បីគាំទ្រផ្នែកច្បាប់ដល់កិច្ចប្រតិបត្តិការក្នុងខេត្តព្រះសីហនុ ។ ថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ចេញសេចក្តីសម្រេចលេខ ៦២សសរ. ស្តីពីការបង្កើតក្រុមការងារបង្ក្រាបការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ដឹកនាំដោយ ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីជំរុញការងារប្រតិបត្តិការនេះ ឲ្យបានទូលំទូលាយ គណៈកម្មាធិការជាតិ បានបង្កើតគណៈកម្មការចំពោះកិច្ចមួយទៀត ដើម្បីធ្វើអធិការកិច្ច ដែលដឹកនាំដោយ ឯកឧត្តម នៅ លក្ខិណា។

គិតចាប់ពីថ្ងៃទី១៨ ខែសីហា រហូតមកដល់ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២នេះ ចំនួនបណ្តឹងដែលបានបញ្ជូលមក តាមប្រព័ន្ធហ្វេសប៊ុក និងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍ ដែលមានព័ត៌មានច្បាស់ការណ៍ ចំនួនជិត ៣០០ករណី ដែលក្នុងនោះ សកម្មភាពជនល្មើស ធ្វើឡើងក្នុងខេត្តព្រះសីហនុ ច្រើនជាងគេ រហូតដល់ជាង ២០០ករណី ។ ក្រុមប្រតិបត្តិការ បានធ្វើសកម្មភាពរុករកជនល្មើស នៅតាមបណ្តាទីតាំងសង្ស័យ តាមសេចក្តីរាយកាណ៍ និងរកឃើញ និងបានសង្គ្រោះជនរងគ្រោះ និងជនដែលពាក់ព័ន្ធនឹងភាពរងគ្រោះ បានរាប់រយនាក់ ក្នុងនោះ មានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ខាំងខ្លួន រឹតត្បិតសេរីភាព និងធ្វើទារុណកម្ម ០៦ករណី មានមនុស្ស ៤៣នាក់ មានបួនសញ្ជាតិ ។ ឃាត់ខ្លួនជនសង្ស័យប្រព្រឹត្តបទល្មើស ២៧នាក់ មានពីរសញ្ជាតិ ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស លួចលាក់ប្រើប្រាស់អាវុធខុសច្បាប់ ចំណែកទីតាំងប្រព្រឹត្តបទល្មើស ត្រូវបានបិទ ដើម្បីធ្វើការស៊ើបអង្កេតប្រមូលភស្តុតាងបន្ថែមទៀត ។ ចំណែកឯជនសង្ស័យ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ធ្វើការសាកសួរ ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុក និងបញ្ជូនទៅតុលាការចាត់ការតាមនីតិវិធី ដើម្បីផ្តន្ទាទោសឲ្យបានស័ក្តិសមនឹងអំពើដែលបានប្រព្រឹត្ត។ មានជនងាយរងគ្រោះរាប់រយនាក់ទៀតដែលបានរកឃើញ ដែលទោះបីជាមិនទាន់ទទួលរងគ្រោះដោយអំពើជួញដូរ ឬធ្វើទារុណកម្មនៅឡើយ តែក៏ត្រូវបានសង្គ្រោះចេញពីទីតាំងដ៏គ្រោះថ្នាក់ និងនាំទៅកាន់ទីតាំងសុវត្ថិភាព ក្រោមកិច្ចសហការ និងសម្របសម្រួលពីបណ្តាស្ថានទូតនៃប្រទេសសាមីដែលមានការពាក់ព័ន្ធ ដើម្បីបានវិលត្រឡប់ទៅកាន់មាតុភូមិ និងជួបជុំក្រុមគ្រួសារវិញដោយសុវត្ថិភាព ។ នៅមានបងប្អូនកូនក្មួយជាច្រើនទៀត ដែលនៅតែមិនលះបង់ជំនឿលើជនល្មើស និងចង់បន្តធ្វើការងារបម្រើឧក្រិដ្ឋជន ទាំងមិនដឹងថាខ្លួនកំពុងស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ឡើយ ។ ជនរងគ្រោះភាគច្រើន

ជាយុវវ័យ ដែលចេះជំនាញបច្ចេកវិទ្យាព័ត៌មានយ៉ាងស្ទាត់ជំនាញ តែនៅតែចាញ់បោកជនល្មើស ឲ្យយកចំណេះដឹងទាំងនេះ ទៅបម្រើឲ្យអំពើឧក្រិដ្ឋ បំផ្លាញខ្លួនឯង និងមនុស្សផងគ្នាទៅវិញ ។ មួយចំនួនទៀត មិនមានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សទេ តែជាករណីលួចលាក់ឆ្លងដែនចូលមកកម្ពុជាដោយខុសច្បាប់ និងសម្ងំលាក់ខ្លួនធ្វើការងារដោយគ្មានការអនុញ្ញាត ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ដើម្បីសម្តែងនូវអំណរគុណចំពោះអង្គទូតនៃប្រទេសពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល បណ្តាញសារព័ត៌មានទាំងអស់ ដែលបានជួយផ្តល់ព័ត៌មានពិតពីអំពើសកម្មភាពជនល្មើស និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសកម្មភាពទុច្ចរិតទាំងឡាយ ដែលបណ្តាញឧក្រិដ្ឋជនបានលបលួចប្រព្រឹត្តក្រោមស្លាកអាជីវកម្មផ្សេងៗនៅកម្ពុជា ដើម្បីអាចឲ្យកម្លាំងសមត្ថកិច្ចអាចបង្ក្រាប និងសង្គ្រោះជនរងគ្រោះបានទាន់ពេលវេលា ។ នេះជាស្មារតីសហការដ៏មានសារសំខាន់ ក្នុងគោលដៅលុបបំបាត់អំពើជួញដូរមនុស្សនៅកម្ពុជា ដែលមិនមែនជាការផ្សព្វផ្សាយ ដោយគ្មានការទទួលខុសត្រូវ ដើម្បីបន្ទុះបង្អាប់កម្ពុជានោះទេ ។ ឧក្រិដ្ឋជនមានកលល្បិចបត់បែន ប្រើគ្រប់មធ្យោបាយ និងព្យាយាមរកឱកាស ដើម្បីកេងប្រវ័ញ្ចតាមគ្រប់រូបភាពលើជនរងគ្រោះ គ្រប់វ័យ គ្រប់ភេទ គ្រប់សញ្ជាតិ ឲ្យតែគេអាចទាក់ទាញ បោកបញ្ឆោតបាន ប្រើប្រាស់បានដោយមិនមានចាំបាច់តែជាប្រជាជននៃប្រទេសក្រីក្រឡើយ ។ នេះជាមូលហេតុ ដែលព្រះរាជាណាចក្រកម្ពុជាបានអំពាវនាវដល់បណ្តាប្រទេសទាំងអស់ ដែលមានការពាក់ព័ន្ធ សូមសហការគ្នា ដើម្បីលុបបំបាត់អំពើជួញដូរមនុស្ស ដែលចាប់ផ្តើមពីការផ្សព្វផ្សាយអប់រំ បង្ការទប់ស្កាត់ ការស៊ើបអង្កេតស្រាវជ្រាវ បង្ក្រាប ការការពារជនរងគ្រោះ ការផ្តន្ទាទោសជនល្មើសឲ្យបានម៉ឺងម៉ាត់ទាំងអស់គ្នា និងទទួលស្គាល់ថានេះជាឧក្រិដ្ឋកម្មឆ្លងដែនដែលមានបណ្តាញចាត់តាំងជាខ្សែសង្វាក់ ពីប្រទេសមួយ ទៅប្រទេសមួយ ។

មុននឹងឈានដល់ការរៀបចំកម្មវិធីនាថ្ងៃនេះ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកដឹកនាំនិកាយសាសនានីមួយៗ ព្រមទាំងអង្គការដៃគូ ដែលបាន និងកំពុងធ្វើការជាមួយប្រជាពលរដ្ឋនៅតាមបណ្តាសហគមន៍មូលដ្ឋាន បានធ្វើការអប់រំផ្ទាល់ដល់ប្រជាពលរដ្ឋដែលមានជំនឿសាសនា និងបានប្រមូលព័ត៌មានអំពីការយល់ដឹងរបស់ប្រជាពលរដ្ឋ ក្នុងសហគមន៍មួយចំនួននៃរាជធានី និងខេត្ត ចំនួន ១៣ គឺ៖ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តមណ្ឌលគីរី ខេត្តព្រះសីហនុ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដោយមានសមាសភាពចូលរួមផ្តល់មតិយោបល់ពី បុគ្គលិកអង្គការ មេឃុំ ក្រុមប្រឹក្សាឃុំ គ្រូបង្រៀន ក្រុមអ្នកស្ម័គ្រចិត្តសុខភាពភូមិ សិស្សានុសិស្ស ប្រជាជន និងយុវជនក្នុងសហគមន៍ កុមារនៅសហគមន៍ក្រីក្រជាយក្រុងភ្នំពេញ សហគមន៍គ្រីស្ទបរិស័ទគណនិកាយប្រូតេស្តង់ សហគមន៍ព្រះកាតូលិក និងពុទ្ធសាសនិកជនសរុប ១.១៥៣នាក់ ក្នុងនោះមានស្ត្រី ចំនួន ៣៤១នាក់ (កុមារ ៣៦នាក់ ក្នុងនោះមានកុមារី ២២នាក់) មានអាយុចន្លោះពី១៥ឆ្នាំ ដល់ ៧០ឆ្នាំ និងបានផ្តល់ព័ត៌មាន ពាក់ព័ន្ធនឹងភាពជាក់ស្តែង និងការយល់ឃើញដូចខាងក្រោម៖

អំពីមូលហេតុដែលនាំឲ្យមានអំពើជួញដូរមនុស្ស មានជាអាទិ៍ គឺបណ្តាលមកពីការកើនឡើងនៃបំណុល បន្ទុកគ្រួសារ ខ្វះជំនាញ ខ្វះការតស៊ូ ខ្វះការងារ ឬមុខរបរ ដែលនាំឲ្យមានចំណូលទៀងទាត់ក្នុងភូមិស្រុកដែលគាត់រស់នៅ មានគ្រោះធម្មជាតិ ធ្វើកសិកម្មមិនមានផលចំណេញ ។ ខ្លះទៀតខ្វះការយកចិត្តទុកដាក់ពីគ្រួសារ ពីអាជ្ញាធរមូលដ្ឋានក្នុងការផ្តល់សេវាចាំបាច់តាមតម្រូវការ មានអំពើហិង្សា ខ្វះការសិក្សាអប់រំ មានការអូសទាញពីមិត្តភក្តិ ក្រុមបងធំ ឬការឆបោកពីមេខ្យល់តាមបណ្តាញសង្គម និងមានអ្នកឃោសនាអូសទាញជ្រើសរើសពលករមិនស្របច្បាប់ ។ មួយចំនួនមិនស្តាប់ការណែនាំ ឬដំបូន្មានដែលរាជរដ្ឋាភិបាល ឬអង្គការដៃគូទាំងឡាយខិតខំផ្សព្វផ្សាយតាមវេទិកាសហគមន៍នានា ដើម្បីភូមិឃុំសង្កាត់មានសុវត្ថិភាព តែបែរជាខិតខំយកចិត្តទុកដាក់លើការអូសទាញរបស់មេខ្យល់ ។ ពោលគឺ ការផ្សព្វផ្សាយអប់រំ ដែលបានធ្វើកន្លងមក មិនមានការទាក់ទាញដូចការបោកបញ្ឆោតរបស់មេខ្យល់នោះទេ ហើយអ្នកទាំងនោះក៏មិនទាន់យល់ពីកលល្បិចជនល្មើស ការកេងប្រវ័ញ្ច ឬអំពើជួញដូរមនុស្សនៅឡើយ ជាពិសេសអ្នករស់នៅតំបន់ជនបទ ។ កត្តាសំខាន់មួយចំនួនទៀតគឺការចាញ់ល្បែងស៊ីសង ការសេពគ្រឿងញៀន គ្រឿងស្រវឹងបំផ្លាញទ្រព្យសម្បត្តិ ប្រព្រឹត្តបទល្មើស គេចវេសពីសំណាញ់ច្បាប់ ការកើនឡើងនូវក្តីបកំសាន្តអូសទាញផ្លូវភេទ អំពើហិង្សា និងការបែកបាក់ក្នុងគ្រួសារ ដែលបណ្តាលឲ្យមនុស្សទាំងនោះ ក្លាយជាជនងាយរងគ្រោះ ដោយការអូសទាញពីមេខ្យល់ ឲ្យចាកចេញពីគ្រួសារ និងចូលក្នុងអន្ទាក់នៃជនល្មើសជួញដូរមនុស្ស ។

ជនដែលរងគ្រោះ គឺជាអ្នកចាកចេញពីគ្រួសារដោយប្រថុយប្រថាន ទៅស្វែងរកលាភសក្ការៈតាមការអូសទាញរបស់មេខ្យល់។ ចំណែកឯការអនុវត្តច្បាប់ក្នុងការបង្ក្រាបអំពើអាណាចារ ល្បែងស៊ីសង និងជនខិលខូចដែលជាមេខ្យល់នៅមានកម្រិត ។

ទាំងនេះគឺជាកង្វល់របស់ប្រជាពលរដ្ឋ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែមទៀត លើការអប់រំផ្សព្វផ្សាយ អំពីកលល្បិចជនល្មើស ការពង្រឹងសុវត្ថិភាពក្នុងសហគមន៍ ការបង្កើនឱកាសការងារ និងមុខរបរសម្រាប់ប្រជាពលរដ្ឋកម្រិតខ្នាតតូច និងមធ្យម ការពង្រឹងការដាំដុះ ការចិញ្ចឹមសត្វ សម្រាប់សុវត្ថិភាពស្បៀង និងត្រូវបង្កើនការបង្ក្រាប និងពង្រឹងការអនុវត្តច្បាប់ ឲ្យបានម៉ឺងម៉ាត់ លើការជួញដូរ ចែកចាយ ប្រើប្រាស់គ្រឿងញៀន ល្បែងស៊ីសងខុសច្បាប់គ្រប់រូបភាព ដែលនាំឲ្យមានអំពើហិង្សា និងការលួចឆក់ប្លន់ និងអសន្តិសុខដល់សហគមន៍ និងត្រូវការកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងដែលនាំឲ្យខូចសុខភាព ។ បង្កើនការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ឲ្យបានទាន់ពេលវេលា ដល់ដៃ និងមានចំណាយទាប ដើម្បីផ្តល់ភាពកក់ក្តៅ និងការជឿជាក់លើអាជ្ញាធរ និងសមត្ថកិច្ច ដែលជាមន្ត្រីរដ្ឋាភិបាល ។

ទន្ទឹមនឹងនោះ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាននិងកំពុងចាត់វិធានការយ៉ាងស្រួចស្រាល់ ក្នុងការធ្វើប្រតិបត្តិការរុករកដើម្បីសង្គ្រោះជនរងគ្រោះ ព្រមទាំងបង្ក្រាបបទល្មើស និងចាប់ជនប្រព្រឹត្តបទល្មើសដើម្បីធ្វើការផ្តន្ទាទោស និងចាត់វិធានការតាមផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ រាល់ករណីបទល្មើសដែលបានរកឃើញ ដោយមិនមានការលើកលែង ។ ទាំងក្រសួងមហាផ្ទៃ ដែលរួមទាំងអគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ និងអាជ្ញាធរដែនដី ក្រសួងយុត្តិធម៌ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងពាក់ព័ន្ធមួយចំនួនទៀត បាន និងកំពុងធ្វើការងារយ៉ាងសកម្ម ក្នុងការជានាឲ្យកិច្ចប្រតិបត្តិការបានទទួលជោគជ័យ ក្នុងការឆ្លើយតបទៅនឹងស្ថានភាពដ៏អាក្រក់នេះ ព្រមទាំងដើម្បីប៉ាន់ប្រមាណពីទំហំនៃបញ្ហា និងវិធានការឆ្លើយតបឲ្យបានទាន់ពេលវេលា ។

លើសពីនេះទៅទៀត ការចូលរួមពីវិស័យសាសនា គឺជាយន្តការនៃការផ្សព្វផ្សាយដ៏មានសក្តានុពល និងប្រសិទ្ធភាព ក្នុងការជួយផ្សព្វផ្សាយ អប់រំដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ឲ្យបានយល់ច្បាស់ពីបំណងប្រាថ្នា និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពីគុណវិបត្តិនៃការប្រព្រឹត្តអំពើហិង្សា អមនុស្សធម៌ អំពើជួញដូរមនុស្ស និងបទល្មើសផ្សេងៗទៀត ដល់ប្រជាជន តាមភូមិ ឃុំ វត្តអារាម ព្រះវិហារ សាលារៀន មន្ទីរពេទ្យ ទីផ្សារ និងកន្លែងប្រមូលផ្តុំនានា ។ល។

ជាទីបញ្ចប់នេះ ខ្ញុំព្រះករុណាខ្ញុំ សូមលំឱនកាយថ្វាយព្រះសព្ទសាធុកាពរ ថ្វាយចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវសមាជិកដ៏ឧត្តុង្គឧត្តមនៃព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ ជាតំណាងអង្គទូត និងស្ថានតំណាងនានាប្រចាំនៅកម្ពុជា ថ្នាក់ដឹកនាំគ្រប់និកាយសាសនា ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកានៃកម្មវិធីទាំងមូល សូមប្រកបដោយ ពរទាំងឡាយពីព្រះជាម្ចាស់ និងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរព្រះគុណ សូមអរគុណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កម្មវិធី

## វេទិកាជាតិអន្តរសាសនាប្រឆាំងការជួញដូរមនុស្ស និងទាសភាពសម័យទំនើប
## លើកទី៦ ឆ្នាំ២០២២
## ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត

**ថ្ងៃព្រហស្បតិ៍ ៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦**
**ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២**
**នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ**

| | | |
|---|---|---|
| **០៦:០០-០៧:៣០** | **៖** | ជួបជុំសមាជិក សមាជិកា តំណាងសាសនាគ្រប់និកាយ |
| **០៧:៣០-០៨:០០** | **៖** | គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ អញ្ជើញដល់ |
| **០៨:០០** | **៖** | **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** អញ្ជើញដល់ |

## <u>ចាប់ផ្តើមកម្មវិធី</u>

- គោរពទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- ការសូត្រធម៌/អធិដ្ឋានបញ្ជូនសារ របស់សាសនានីមួយៗ(មួយក្រុមសាសនា ៥នាទី)
- សុន្ទរកថា និងរបាយការណ៍ស្ថានភាពជួញដូរមនុស្ស (ជាសកល និងនៅកម្ពុជា) និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការឆ្លើយតប ដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- សុន្ទរកថា និងប្រសាសន៍សំណេះសំណាលដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** អញ្ជើញនិវត្តន៍ ។

<u>**ចប់កម្មវិធី**</u>